បច្ចុប្បន្នភាពស្តីអំពីការបើកទ្វារសាលារៀន ពីអគ្គនាយក បេគ័រ

សហគមន៍ក្រសួងអប់រំឡុងប៊ីចជាទីមេត្រី

ដូចដែលបានសន្យា ខ្ញុំសូមផ្តល់បច្ចុប្បន្នភាពស្តីអំពីផែនការបើកទ្វារសាលារបស់យើង។ គ្រូបង្រៀននិងបុគ្គលិកសាលាយើងបានធ្វើការយ៉ាងមមារញឹករៀបចំជំរើសនៃការរៀនសូត្រដែលល្អបំផុតសម្រាប់កូនលោកអ្នក ខណៈដែលទុកសុវត្ថិភាពជាអាទិភាពខ្ពស់ជាងគេរបស់យើង ដោយសារតែការរាតត្បាតនៃរោគក្លូវ៉ូណាវិរុសនេះ។ យើងបន្តធ្វើការគិតគូពិចារណាដល់ការណែនាំជាបន្តបន្ទាប់ពីក្រសួងសុខភាពរដ្ឋនិងក្រុងព្រមទាំងអង្គការសុខភាពនានាផងដែរ ហើយយើងមានសេចក្តីរីករាយនឹងចែករំលែកនូវផែនការបើកសាលានិងសុវត្ថិភាពសម្រាប់ឆ្នាំសិក្សា២០២០-២០២១។ ផែនការនេះក៏មានចុះផ្សាយនៅក្នុងគេហៈទំព័រ lbschools.net/coronavirus, ដែលជាកន្លែងដែលយើងផ្តល់បច្ចុប្បន្នភាព។ នៅប៉ុន្មានថ្ងៃខាងមុខនេះ យើងក៏នឹងផ្តល់ការបកប្រែជាភាសាស្ប៉ែនិសនិងខ្មែរផងដែរ។ ប្រធានបទនៅក្នុងផែនការនេះមានរួមនូវៈ

- វិធីការសុខភាពនិងសុវត្ថិភាព
- ការធ្វើតែស្ត COVID-19 និងរបាយការណ៍
- វិធីការជូតសម្អាតអគារនិងការសម្លាប់មេរោគ
- កម្មវិធីបង្ហាត់បង្រៀន
- ការអប់រំពិសេសនិងសុខភាពផ្លូវចិត្ត
- កម្មវិធីកីឡានិងសកម្មភាពក្រៅម៉ោងសាលា

ដូចដែលយើងបានចែករំលែកនៅក្នុងទំនាក់ទំនងសហគមន៍ពីសប្តាហ៍កន្លងមក ការិយាល័យសាលានឹងរង់ចាំទទួលឆ្លើយសំណួរផ្សេងៗអំពីកម្មវិធីបង្ហាត់បង្រៀន និងការដាក់ដំណើរការច្បាស់លាស់របស់សាលារៀននីមួយៗ។ ក្នុងពេលឆាប់ៗនេះ លោកអ្នកនឹងបានទទួលដំណឹងពីសាលារៀនស្តីពីនីតិវិធីទៅយកសម្ភារៈសិក្សា ការទៅយកកុំព្យូទ័រ ក្រុមប៊ុត និងការគាំទ្រសម្រាប់ប្រើប្រាសប្រព័ន្ធចាត់ចែងកម្មវិធីរៀនសូត្រថ្មីរបស់យើង ដែលនឹងភ្ជាប់សិស្សគ្រប់រូបនិងគ្រួសារផ្ទាល់ជាមួយគ្រូបង្រៀននិងបុគ្គលិកសាលាតែម្តង។

យើងកំពុងមានការលូតលាស់នៅក្នុងការចរចារជាផ្លូវការជាមួយអង្គការសហជីបគ្រូបង្រៀននៅឡុងប៊ីច Teachers Association of Long Beach ដើម្បីព្រមព្រៀងគ្នាលើករណីផ្សេងៗស្តីពីឆ្នាំសិក្សាថ្មី ហើយយើងសង្ឃឹមថានឹងផ្តល់បច្ចុប្បន្នភាពមួយទៀតនៅដើមសប្តាហ៍ក្រោយ។

សូមអរគុណដល់ការគាំទ្រនិងអំណត់ធ្មត់របស់លោកអ្នកខណៈដែលយើងបន្តពុះពារឆ្លងកាត់ពេលវេលាដ៏លំបាកនេះជាមួយគ្នាជាសហគមន៍មួយ។

សូមអរគុណ

Jill Baker ជៀល បេគ័រ
អគ្គនាយកនៃការអប់រំ